**ព្រះរាជាណាចក្រកម្ពុជា**
ជាតិ សាសនា ព្រះមហាក្សត្រ

**រាជរដ្ឋាភិបាលកម្ពុជា**
**ក្រសួងមហាផ្ទៃ**
លេខ: [illegible]

**ជម្រាបមក**

**-ឯកឧត្តម លោកជំទាវអភិបាល នៃគណៈអភិបាលរាជធានី ខេត្ត**

**-លោក លោកស្រី អភិបាល នៃគណៈអភិបាលក្រុង ស្រុក ខណ្ឌ**

**<u>កម្មវត្ថុ</u>** ៖ ស្តីពីការរៀបចំ និងកសាងផែនការអភិវឌ្ឍន៍រយៈពេលប្រាំឆ្នាំ (២០២៥-២០២៩) របស់រដ្ឋបាលរាជធានី ខេត្ត ក្រុង ស្រុក ខណ្ឌ។

**<u>យោង</u>** ៖- ព្រះរាជក្រមលេខ នស/រកម/០៥០៨/០១៧ ចុះថ្ងៃទី២៤ ខែឧសភា ឆ្នាំ២០០៨ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការគ្រប់គ្រងរដ្ឋបាលរាជធានី ខេត្ត ក្រុង ស្រុក ខណ្ឌ

- អនុក្រឹត្យលេខ២១៩ អនក្រ.បក ចុះថ្ងៃទី១៤ ខែធ្នូ ឆ្នាំ២០០៩ ស្តីពីផែនការអភិវឌ្ឍ និងកម្មវិធីវិនិយោគបីឆ្នាំរំកិលរាជធានី ខេត្ត ក្រុង ស្រុក ខណ្ឌ។

សេចក្តីដូចមានចែងក្នុងកម្មវត្ថុ និងយោងខាងលើ សូមជម្រាបជូន**ឯកឧត្តម លោកជំទាវ អភិបាល នៃគណៈអភិបាលរាជធានី ខេត្ត និងលោក លោកស្រី អភិបាល នៃគណៈអភិបាលក្រុង ស្រុក ខណ្ឌ** ជ្រាបថា ផ្អែកតាមច្បាប់ស្តីពីការគ្រប់គ្រងរដ្ឋបាលរាជធានី ខេត្ត ក្រុង ស្រុក ខណ្ឌ ក្រុមប្រឹក្សារាជធានី ខេត្ត ក្រុង ស្រុក ខណ្ឌ អាណត្តិទី៤ ដែលទើបប្រកាសចូលកាន់តំណែងថ្មីត្រូវរៀបចំផែនការអភិវឌ្ឍន៍រយៈពេលប្រាំឆ្នាំនៃអាណត្តិរបស់ខ្លួន ដើម្បីដាក់ចេញនូវចក្ខុវិស័យក្នុងការអភិវឌ្ឍមូលដ្ឋានប្រកបដោយប្រសិទ្ធភាព តម្លាភាព គណនេយ្យភាព និងបរិយាប័ន្ន។

លើមូលដ្ឋាននេះ ដើម្បីឱ្យការរៀបចំ និងការកសាងផែនការអភិវឌ្ឍន៍រយៈពេលប្រាំឆ្នាំ (២០២៥-២០២៩) របស់ក្រុមប្រឹក្សារាជធានី ខេត្ត ក្រុង ស្រុក ខណ្ឌ អាណត្តិទី៤ ប្រព្រឹត្តទៅដោយរលូន ទាន់ពេលវេលាកំណត់ និងទទួលបានលទ្ធផលល្អប្រសើរ ក្រសួងមហាផ្ទៃសូមធ្វើការណែនាំដល់**ឯកឧត្តម លោកជំទាវ អភិបាល នៃគណៈអភិបាលរាជធានី ខេត្ត និងលោក លោកស្រី អភិបាល នៃគណៈអភិបាលក្រុង ស្រុក ខណ្ឌ** ចាត់ចែងអនុវត្តនូវកិច្ចការសំខាន់ៗមួយចំនួន ដូចខាងក្រោម៖

១- ក្រុមប្រឹក្សារាជធានី ក្រុមប្រឹក្សាខេត្ត ក្រុមប្រឹក្សាក្រុង ក្រុមប្រឹក្សាស្រុក ក្រុមប្រឹក្សាខណ្ឌ ត្រូវរៀបចំ និងកសាងផែនការអភិវឌ្ឍន៍រយៈពេលប្រាំឆ្នាំ (២០២៥-២០២៩) ឱ្យបានចប់សព្វគ្រប់ក្នុងឆ្នាំទី១ នៃអាណត្តិរបស់ខ្លួនដោយត្រូវបញ្ចប់ឱ្យបានរួចរាល់**យ៉ាងយូរត្រឹមដំណាច់ខែមិថុនា ឆ្នាំ២០២៥។**

២- ត្រូវបង្កើតក្រុមការងារទទួលបន្ទុករៀបចំ និងកសាងផែនការអភិវឌ្ឍន៍រយៈពេលប្រាំឆ្នាំ (២០២៥-២០២៩) និងកម្មវិធីវិនិយោគបីឆ្នាំរំកិល និងស្របតាមគោលការណ៍ និងនីតិវិធីដែលមានចែងក្នុងច្បាប់ លិខិតបទដ្ឋានគតិយុត្ត និងសេចក្តីណែនាំបច្ចេកទេសនានាជាធរមាន។

៣- ត្រូវរៀបចំប្រតិទិនការងារស្តីពីការរៀបចំ និងកសាងផែនការអភិវឌ្ឍន៍រយៈពេលប្រាំឆ្នាំ (២០២៥-២០២៩) ឱ្យបានទាន់ពេលវេលាកំណត់។

៤- ត្រូវចាប់ផ្តើមការរៀបចំ និងកសាងផែនការអភិវឌ្ឍន៍រយៈពេលប្រាំឆ្នាំ (២០២៥-២០២៩) ស្របតាមគោលការណ៍ និងនីតិវិធីដែលមានចែងក្នុងច្បាប់ និងលិខិតបទដ្ឋានគតិយុត្តជាធរមាន។ ការរៀបចំ និងកសាងផែនការនេះ ត្រូវឆ្លុះបញ្ចាំង និងឆ្លើយតបនឹងគោលបំណង និងគោលដៅអាទិភាពនៃយុទ្ធសាស្ត្របញ្ចកោណដំណាក់កាលទី១ របស់រាជរដ្ឋាភិបាលនីតិកាលទី៧ នៃរដ្ឋសភា រួមទាំងកម្មវិធីនយោបាយអាទិភាពនានារបស់ថ្នាក់ជាតិដោយផ្តោតលើវិស័យជាអាទិភាពក្នុងការជំរុញដល់កំណើនសេដ្ឋកិច្ចនៅមូលដ្ឋានជួយលើកកម្ពស់ជីវភាព និងតម្រូវការចាំបាច់នានារបស់ប្រជាពលរដ្ឋ។

៥- ត្រូវធ្វើសេចក្តីសម្រេចបង្កើតក្រុមការងារទទួលបន្ទុករៀបចំ និងកសាងផែនការអភិវឌ្ឍន៍រយៈពេលប្រាំឆ្នាំ (២០២៥-២០២៩) និងកម្មវិធីវិនិយោគបីឆ្នាំរំកិល (២០២៥-២០២៧) និងប្រតិទិនការងារនៃការរៀបចំ និងកសាងផែនការអភិវឌ្ឍន៍រយៈពេលប្រាំឆ្នាំ (២០២៥-២០២៩) និងត្រូវបញ្ជូនព័ត៌មានស្តីពីវឌ្ឍនភាពការងារកសាងផែនការអភិវឌ្ឍន៍រយៈពេលប្រាំឆ្នាំ (២០២៥-២០២៩) របស់រដ្ឋបាលរាជធានី ខេត្ត ក្រុង ស្រុក ខណ្ឌ ជូនមកក្រសួងមហាផ្ទៃ រៀងរាល់**បី(០៣)ខែម្តង** តាមទម្រង់គំរូដូចមានជូនភ្ជាប់ជាមួយ។

ទន្ទឹមនេះ រដ្ឋបាលរាជធានី ខេត្ត ត្រូវធ្វើការណែនាំ ជំរុញ និងគាំទ្រដល់រដ្ឋបាលក្រុង ស្រុក ខណ្ឌ ក្នុងការរៀបចំ និងកសាងផែនការអភិវឌ្ឍន៍រយៈពេលប្រាំឆ្នាំ (២០២៥-២០២៩) និងកម្មវិធីវិនិយោគបីឆ្នាំរំកិល (២០២៥-២០២៧)។

ព័ត៌មានបន្ថែម និងការបញ្ជូនឯកសារ និងព័ត៌មានផ្សេងៗជូនមកក្រសួងមហាផ្ទៃលើការងារខាងលើនេះ សូមធ្វើការទំនាក់ទំនង លោក **វ៉ែន សំណាង** ប្រធានការិយាល័យ តាមរយៈលេខទូរសព្ទ ០១២ ៣១៥ ១១១ និងលោក **ព្រោន មុនីភាព** ប្រធានការិយាល័យ តាមរយៈលេខទូរសព្ទ ០១២ ៧១១ ៧២០។

អាស្រ័យហេតុនេះ សូម **ឯកឧត្តម លោកជំទាវ អភិបាល នៃគណៈអភិបាលរាជធានី ខេត្ត និង លោក លោកស្រី អភិបាល នៃគណៈអភិបាលក្រុង ស្រុក ខណ្ឌ** ជ្រាប និងចាត់ចែងអនុវត្តតាមខ្លឹមសារខាងលើប្រកបដោយស្មារតីទទួលខុសត្រូវខ្ពស់។

សូម **ឯកឧត្តម លោកជំទាវ** លោក លោកស្រី ទទួលនូវការគោរពអំពីខ្ញុំ។

ថ្ងៃ សុក្រ ១០ កើត ខែ ភទ្របទ ឆ្នាំរោង ឆស័ក ព.ស.២៥៦៨

រាជធានីភ្នំពេញ ថ្ងៃទី ១៣ ខែ កញ្ញា ឆ្នាំ២០២៤

**ឧបនាយករដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងមហាផ្ទៃ**

**អគ្គបណ្ឌិតសភាចារ្យ ស សុខា**

**ចម្លងជូន** :
- ទីស្តីការគណៈរដ្ឋមន្ត្រី
- ក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ
- ក្រសួងផែនការ
- ខុទ្ទកាល័យសម្តេចមហាបវរធិបតីនាយករដ្ឋមន្ត្រី
- ឯកសារ-កាលប្បវត្តិ

(គំរូរបាយការណ៍របស់រាជធានី)

**ព្រះរាជាណាចក្រកម្ពុជា**

**ជាតិ សាសនា ព្រះមហាក្សត្រ**

**និមិត្តសញ្ញា**

**រដ្ឋបាល...........**

លេខ...................

## សូមគោរពជូន

### ឯកឧត្តមអគ្គបណ្ឌិតសភាចារ្យ ស សុខា ឧបនាយករដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងមហាផ្ទៃ

**កម្មវត្ថុ** ៖ របាយការណ៍វឌ្ឍនភាពស្តីពីការរៀបចំ និងកសាងផែនការអភិវឌ្ឍន៍រយៈពេលប្រាំឆ្នាំ ២០២៥-២០២៩ របស់រដ្ឋបាលរាជធានីភ្នំពេញ និងរដ្ឋបាលខណ្ឌ។

**យោង** ៖ លិខិតលេខ........... ចុះថ្ងៃទី..... ខែ.......... ឆ្នាំ២០២៤ របស់ក្រសួងមហាផ្ទៃ។

សេចក្តីដូចមានចែងក្នុងកម្មវត្ថុ និងយោងខាងលើ ខ្ញុំសូមគោរពជម្រាបជូន **ឯកឧត្តមអគ្គបណ្ឌិតសភាចារ្យ ស សុខា ឧបនាយករដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងមហាផ្ទៃ** មេត្តាជ្រាបដ៏ខ្ពង់ខ្ពស់អំពីរបាយការណ៍វឌ្ឍនភាពនៃការរៀបចំ និងកសាងផែនការអភិវឌ្ឍន៍រយៈពេលប្រាំឆ្នាំ (២០២៥-២០២៩) របស់រដ្ឋបាលរាជធានីភ្នំពេញ និងរដ្ឋបាលខណ្ឌ ដូចខាងក្រោម៖

**១.ការរៀបចំ និងកសាងផែនការអភិវឌ្ឍន៍រយៈពេលប្រាំឆ្នាំ (២០២៥-២០២៩) របស់រដ្ឋបាលរាជធានីភ្នំពេញ**

គិតត្រឹមថ្ងៃ......ខែ..............ឆ្នាំ២០២... ក្រុមការងារកសាងផែនការបានអនុវត្តដល់សកម្មភាពទី...នៃជំហានទី.....ស្មើនឹង...%។

បញ្ហាប្រឈមរបស់រដ្ឋបាលរាជធានីភ្នំពេញ ក្នុងការរៀបចំ និងកសាងផែនការអភិវឌ្ឍន៍ រួមមាន៖

| បញ្ហាប្រឈម | ដំណោះស្រាយ/សំណូមពរ |
|---|---|
| | |
| | |
| | |
| | |
| | |
| | |

**២.ការរៀបចំ និងកសាងផែនការអភិវឌ្ឍន៍រយៈពេលប្រាំឆ្នាំ (២០២៥-២០២៩) របស់រដ្ឋបាលក្រុង ស្រុក នៃរដ្ឋបាលខេត្ត........**

គិតត្រឹមថ្ងៃ......ខែ.............ឆ្នាំ២០២... រដ្ឋបាលក្រុង ស្រុក នៃខេត្ត.............................. បានអនុវត្តដល់សកម្មភាព និងជំហានដូចខាងក្រោម៖

| ល.រ | ឈ្មោះរដ្ឋបាលខណ្ឌ | ជំហានទី១ | ជំហានទី២ | ជំហានទី៣ | សម្គាល់ |
|---|---|---|---|---|---|
| ១ | | ✓ | | | សកម្មភាពទី៣ (ឈ្មោះសកម្មភាព......) |
| ២ | | | ✓ | | |
| ៣ | | | | ✓ | |
| ៤ | | | | | |
| ៥ | | | | | |

បញ្ហាប្រឈមរបស់រដ្ឋបាលក្រុង ស្រុក ក្នុងការរៀបចំ និងកសាងផែនការអភិវឌ្ឍន៍ រួមមាន៖

| បញ្ហាប្រឈម | ដំណោះស្រាយ/សំណូមពរ |
|---|---|
| | |
| | |
| | |
| | |
| | |

សេចក្តីដូចបានគោរពជម្រាបជូនខាងលើ សូម **ឯកឧត្តមអភិសន្តិបណ្ឌិត ស សុខា ឧបនាយករដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងមហាផ្ទៃ** មេត្តាជ្រាបជារបាយការណ៍ដ៏ខ្ពង់ខ្ពស់។

សូម **ឯកឧត្តមអភិសន្តិបណ្ឌិត ឧបនាយករដ្ឋមន្ត្រី** មេត្តាទទួលនូវការគោរពដ៏ខ្ពង់ខ្ពស់ អំពីខ្ញុំ។

ថ្ងៃ.................ខែ....................ឆ្នាំ.................ព.ស.២៥៦...

...................., ថ្ងៃទី.....ខែ............................ឆ្នាំ២០២...

**អភិបាល នៃគណៈអភិបាលខេត្ត**

(ហត្ថលេខា ត្រា និងឈ្មោះ)

*(គំរូរបាយការណ៍របស់រដ្ឋបាលខេត្ត)*

**ព្រះរាជាណាចក្រកម្ពុជា**

**ជាតិ សាសនា ព្រះមហាក្សត្រ**

**និមិត្តសញ្ញា**

**រដ្ឋបាល...........**

លេខ...................

**សូមគោរពជូន**

**ឯកឧត្តមអភិសន្តិបណ្ឌិត ស សុខា ឧបនាយករដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងមហាផ្ទៃ**

**<u>កម្មវត្ថុ</u>** ៖ របាយការណ៍វឌ្ឍនភាពស្តីពីការរៀបចំ និងកសាងផែនការអភិវឌ្ឍន៍រយៈពេលប្រាំឆ្នាំ ២០២៥-២០២៩ របស់រដ្ឋបាលខេត្ត.............និងរដ្ឋបាលក្រុង ស្រុក នៃខេត្ត...............។

**<u>យោង</u>** ៖ លិខិតលេខ ............. ចុះថ្ងៃទី..... ខែ......... ឆ្នាំ២០២៤ របស់ក្រសួងមហាផ្ទៃ។

សេចក្តីដូចមានចែងក្នុងកម្មវត្ថុ និងយោងខាងលើ ខ្ញុំសូមគោរពជម្រាបជូន **ឯកឧត្តមអភិសន្តិបណ្ឌិត ស សុខា ឧបនាយករដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងមហាផ្ទៃ** មេត្តាជ្រាបដ៏ខ្ពង់ខ្ពស់អំពីរបាយការណ៍វឌ្ឍនភាពនៃការរៀបចំ និងកសាងផែនការអភិវឌ្ឍន៍រយៈពេលប្រាំឆ្នាំ (២០២៥-២០២៩) របស់រដ្ឋបាលខេត្ត ក្រុង ស្រុក ដូចខាងក្រោម៖

**១.ការរៀបចំ និងកសាងផែនការអភិវឌ្ឍន៍រយៈពេលប្រាំឆ្នាំ (២០២៥-២០២៩) របស់រដ្ឋបាលខេត្ត............**

គិតត្រឹមថ្ងៃ......ខែ..............ឆ្នាំ២០២... ក្រុមការងារកសាងផែនការបានអនុវត្តដល់សកម្មភាពទី...នៃជំហានទី.....ស្មើនឹង....%។

បញ្ហាប្រឈមរបស់រដ្ឋបាលខេត្ត............... ក្នុងការរៀបចំ និងកសាងផែនការអភិវឌ្ឍន៍ រួមមាន៖

| បញ្ហាប្រឈម | ដំណោះស្រាយ/សំណូមពរ |
|---|---|
| | |
| | |
| | |
| | |
| | |
| | |
| | |

ឞ